មជ្ឈមណ្ឌលឯកសារកម្ពុជា

# កេរដំណែលនៃសាលាក្តីខ្មែរក្រហមសម្រាប់ប្រព័ន្ធតុលាការកម្ពុជា

ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៥

***លីម ជ័យឧត្តម***

***អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម***

***មជ្ឈមណ្ឌលឯកសារកម្ពុជា***

ចាប់តាំងពីការចាប់ផ្តើមនៃគម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម នៅក្នុងខែមេសា ឆ្នាំ២០១១ សមាជិកក្រុមនៃគម្រោងនេះ បានចូលរួមសង្កេតការណ៍នៅគ្រប់សវនាការនៃសំណុំរឿង០០២ ដំណាក់កាលទី១ (ឬហៅម្យ៉ាងទៀតថា សំណុំរឿង០០២/០១) ទាំង២១២ថ្ងៃ រហូតដល់ថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមផ្តន្ទាទោសអតីតមេដឹកនាំខ្មែរក្រហម នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត នៅពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ។ សវនាការជំនុំជម្រះក្តីលើបទឧក្រិដ្ឋកម្មអន្តរជាតិដែលមានការចូលរួមពីសំណាក់អ្នកច្បាប់ជាតិ និងអន្តរជាតិ បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពខុសប្លែកគ្នាពីរបៀបនៃការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីក្នុងសវនាការ និងយុទ្ធសាស្ត្ររបស់គូភាគីដែលប្រើប្រាស់ក្នុងការលើកឡើងនូវអំណះអំណាងនៅចំពោះមុខតុលាការ ដែលកម្រឃើញមានអនុវត្តនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជា ។

អ្នកជំនាញ អ្នកច្បាប់ អ្នកឃ្លាំមើលដំណើរការសវនាការទាំងជាតិ និងអន្តរជាតិ ជាច្រើនរូបបានបង្ហាញពីមតិយោបល់ផ្សេងគ្នាជុំវិញកេរដំណែលនៃសាលាក្តីខ្មែរក្រហម ដោយខ្លះយល់ឃើញថាសាលាក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនឹងក្លាយទៅជាតុលាការគំរូមួយសម្រាប់តុលាការជាតិកម្ពុជា និងខ្លះទៀតយល់ថា តុលាការចម្រុះមួយនេះនៅពុំទាន់អាចធ្វើជាតុលាការគំរូសម្រាប់ប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជាបានឡើយបាននៅឡើយ ។

យោងតាមបទពិសោធន៍នៃការសង្កេតជាក់ស្តែង របស់គម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម ទោះបីជាសាលាក្តីខ្មែរក្រហមពុំបានជះឥទ្ធិពលគ្របដណ្តប់ទាំងស្រុងលើទម្លាប់នៃការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែវាពិតបានផ្តល់នូវផលជាវិជ្ជមានចំពោះប្រព័ន្ធច្បាប់របស់កម្ពុជាដោយពុំអាចប្រកែកបាន ។ សាលាក្តីខ្មែរក្រហមបានផ្តល់នូវបទពិសោធន៍ និងគំរូនៃការអនុវត្តដល់មន្ត្រីអនុវត្តច្បាប់ និងបុគ្គលិកបម្រើការសម្រាប់ភាគីជាតិ ទាំងផ្នែកបច្ចេកទេស និងផ្នែកនីតិវិធី ហើយប្រភពធនធានទាំងនោះនឹងក្លាយជាទុនយ៉ាងសំខាន់សម្រាប់ប្រើប្រាស់នៅក្នុងប្រព័ន្ធតុលាការជាតិ នៅពេលដែលអ្នកទាំងនោះត្រឡប់ទៅបម្រើការងារនៅក្នុងស្ថាប័នរបស់ខ្លួនវិញ ។

ចំណុចខាងក្រោមនឹងពិភាក្សាអំពីតួនាទីរបស់សាលាក្ដីខ្មែរក្រហម ថាតើតុលាការចម្រុះមួយនេះអាចនឹងដើរតួនាទីជាគំរូសម្រាប់ប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជាបានដែរឬយ៉ាងណា ។

## ក្ដីរំពឹងអំពីកេរដំណែលនៃសាលាក្ដីខ្មែរក្រហម

នៅស្របពេលដែលប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្នត្រូវបានសាធារណជនទូទៅមើលឃើញថានៅមានសភាពអន់ខ្សោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានរំពឹងថានឹងអាចក្លាយទៅជាតុលាការគំរូមួយសម្រាប់តុលាការក្នុងស្រុក ក្នុងការចូលរួមចំណែកធ្វើឲ្យមានការផ្លាស់ប្ដូរមួយក្នុងរយៈពេលវែងទាក់ទងនឹងការលើកកម្ពស់សមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ និងទទួលបាននូវចំណេះដឹង និងជំនាញបន្ថែមពីសំណាក់សហគមន៍អន្តរជាតិ ។ អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ ធ្លាប់បានថ្លែងនៅអំឡុងពេលនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយព្យាករណ៍ទុកជាមុនថា សាលាក្ដីខ្មែរក្រហមនឹងបន្សល់ទុកនូវកេរដំណែលដ៏មានតម្លៃមួយសម្រាប់ប្រទេសកម្ពុជា ហើយជំនាញ និងចំណេះដឹងដែលកើតចេញពីសាលាក្ដីនេះនឹងត្រូវផ្ទេរទៅបុគ្គលិកជាតិ និងអ្នកពាក់ព័ន្ធ ៖

> *យើងមានក្ដីសង្ឃឹមថា ការបង្កើតឡើងនូវដំណើរការច្បាស់លាស់មួយដែលគោរពតាមបទដ្ឋានអន្តរជាតិ និងជះឥទ្ធិពលផ្នែកអប់រំទៅលើស្ថាប័នដែលកំពុងដំណើរការផ្សេងការបច្ចុប្បន្ន និងបណ្ដុះស្មារតីក្នុងចំណោមប្រជាជនទូទៅឲ្យយល់ដឹងពីការពិតពាក់ព័ន្ធនឹងអតីតកាលដែលពោរពេញដោយភាពវិនាសអន្តរាយរបស់កម្ពុជា និងការទាមទារបន្ថែមទៀតឲ្យមានប្រព័ន្ធតុលាការមួយដែលនឹងបំពេញមុខនាទីត្រឹមត្រូវ ។*[១]

អង្គជំនុំជម្រះសាលាដំបូង ក៏ធ្លាប់បានទទួលស្គាល់អំពីសារសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះចំណុចនេះ ដោយបានកត់សម្គាល់ថា *"ក្នុងនាមជាតុលាការគំរូ...អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដើរតួនាទីក្នុងការជំរុញ និងសង្កត់ធ្ងន់លើសារសំខាន់នៃការការពារឯករាជភាព និងសុចរិតភាពនៃប្រព័ន្ធតុលាការ"* ។[២] បន្ថែមពីលើនេះ មន្ត្រីជាន់ខ្ពស់នៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ជាច្រើនលើកច្រើនសាថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការគំរូ ។[៣]

---

[១] *ដកស្រង់ចេញពីអត្ថបទ Situation of Human Rights in Cambodia, ដែលដាក់ជូនគណៈកម្មាការសិទ្ធិមនុស្ស,* U.N. Doc. E/CN.4/2005/116, *កថាខណ្ឌ១៩ (នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៤) ។*

[២] *សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្តរបស់ក្រុមមេធាវីការពារក្ដី អៀង សារី ដែលស្នើសុំដកចៅក្រម និល ណុន, សូមមើលកំណត់សម្គាល់ជើងទំព័រទី៩, កថាខណ្ឌ១៤ ។*

[៣] *សូមមើល, លោកឧបនាយករដ្ឋមន្ត្រី សុខ អាន, ពាក្យសម្ដីនៅក្នុងការក្នុងពិធីធ្វើសម្បថនៃបុគ្គលិកតុលាការជាតិ និងអន្តរជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦, អាចរកបាននៅគេហទំព័រ* http://www.eccc.gov.kh/sites/default/files/media/Sok_An_speech_for_reception_3_July_2006.p

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញពីគោលបំណងរបស់ខ្លួនក្នុងការប្រើប្រាស់លទ្ធភាព ដើម្បីបង្កើនការយល់ដឹងរបស់តុលាការក្នុងស្រុកពាក់ព័ន្ធនឹងបទដ្ឋានអន្តរជាតិ និងការប្រព្រឹត្តទៅនៃការជំនុំជម្រះក្តីដោយយោងតាមគោលការណ៍យុត្តិធម៌អន្តរជាតិ ។

ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃសាលាក្តីខ្មែរក្រហម លោក ក្រាញ់ តូនី ធ្លាប់បានបញ្ជាក់ថា បុគ្គលិកជាតិដែលកំពុងធ្វើការនៅសាលាក្តីខ្មែរក្រហម នឹងក្លាយទៅជាធនធានដ៏មានតម្លៃសម្រាប់ប្រព័ន្ធច្បាប់កម្ពុជា នៅពេលដែលអ្នកទាំងនោះត្រឡប់ទៅបម្រើការងារនៅក្នុងស្ថាប័នក្នុងស្រុករបស់ខ្លួនវិញ ។[៤] ចំណែកឯ លោកចៅក្រម យូ ប៊ុនឡេង ដែលមានតួនាទីជាសហចៅក្រមស៊ើបអង្កេតជាតិនៃសាលាក្តីខ្មែរក្រហម និងមានតួនាទីជាប្រធានតុលាការសាលាឧទ្ធរណ៍នៃតុលាការជាតិកម្ពុជា ធ្លាប់បានលើកឡើងទាក់ទងនឹងបន្ទប់សម្រាប់សាក្សី និងប្រព័ន្ធគ្រប់គ្រងសំណុំរឿងតាមរយៈកុំព្យូទ័រនៅសាលាក្តីខ្មែរក្រហម ដែលរៀបចំឡើងដើម្បីជាការការពារដល់សិទ្ធិរបស់ជនរងគ្រោះ សាក្សី និងជនជាប់ចោទ និងមន្ត្រីតុលាការដែលទទួលបន្ទុកគ្រប់គ្រងកិច្ចការផ្នែករដ្ឋបាល រួមជាមួយនឹងការបោះពុម្ពផ្សាយសេចក្តីសម្រេចរបស់តុលាការតាមរយៈប្រព័ន្ធអ៊ីនធឺណែត ។[៥]

កិច្ចដំណើរការនីតិវិធីនៅសាលាក្តីខ្មែរក្រហមបានបង្រៀនអំពីវិជ្ជាជីវៈក្នុងការអនុវត្តច្បាប់ និងផ្តល់នូវគំរូក្នុងការរៀបចំឥរិយាបថនៅក្នុងសវនាការ ថាតើចៅក្រមគួរមានអាកប្បកិរិយាបែបណា ។ ប្រធានអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហម លោកចៅក្រម និល ណុន ត្រូវបានមើលឃើញថា បានអនុវត្តយ៉ាងល្អប្រសើរនៅក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធីសវនាការ ទាំងការប្រើប្រាស់សូរស័ព្ទ និងឥរិយាបថ ទោះបីជានៅមានចំណុចខ្វះខាតខ្លះៗក៏ដោយ ។ ការប្រើប្រាស់ឥរិយាបថ និងពាក្យសម្តីពុំសមរម្យចំពោះជនជាប់ចោទ សាក្សី ឬជនរងគ្រោះ ពីសំណាក់ចៅក្រមជំនុំជម្រះត្រូវបានមើលឃើញថា បានកើតឡើងជាញឹកញាប់នៅអំឡុងពេលនៃការជំនុំជម្រះក្តីនៅក្នុងស្ថាប័នតុលាការក្នុងស្រុក ។ គំរូក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធីសវនាការនៅសាលាក្តីខ្មែរក្រហមពីសំណាក់ចៅក្រមដែលមានវិជ្ជាជីវៈនឹងអាចក្លាយជាបទពិសោធន៍ល្អសម្រាប់ស្ថាប័នតុលាការជាតិរៀនសូត្រ និងអនុវត្តតាមនៅពេលមានការជំនុំជម្រះក្តី ទាំងការរៀបចំឥរិយាបថ និងការប្រើប្រាស់ពាក្យសម្តីពីសំណាក់ចៅក្រមក្នុងការសួរដេញដោលចំពោះភាគី ។

---

(យើងមានសង្ឃឹម និងរំពឹងទុកយ៉ាងមុតមាំថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងក្លាយជាតុលាការគំរូសម្រាប់កម្ពុជា) ។

[៤] John D. Ciorciari and Anne Heindel, Experiments in International Criminal Justice: Lessons From the Khmer Rouge Tribunal, ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣, ទំព័រ៦៨ ។

[៥] ដូចខាងលើ ។

ទោះបីជាមតិភាគច្រើនទទួលស្គាល់ថា សាលាក្តីខ្មែរក្រហមនឹងក្លាយជាគុលាការគំរូសម្រាប់ប្រព័ន្ធតុលាការក្នុងស្រុកក៏ដោយ អត្ថបទស្រាវជ្រាវមួយដែលមានចំណងជើងថា *«បទពិសោធន៍នៅក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៖ មេរៀនពីសាលាក្តីខ្មែរក្រហម»* បានរកឃើញថា នៅមានភស្តុតាងតិចតួចនៅឡើយ ដែលបង្ហាញថា សាលាក្តីខ្មែរក្រហមអាចជះឥទ្ធិពលវិជ្ជមានដល់ប្រព័ន្ធតុលាការក្នុងស្រុកកម្ពុជា ។ អត្ថបទនោះបានដកស្រង់សម្តីអ្នកវិភាគមួយរូប ដែលបានបង្ហាញពីការយល់ឃើញរបស់ខ្លួនថា ទោះបីជាសាលាក្តីខ្មែរក្រហមបានជួយអភិវឌ្ឍន៍ជំនាញ និងចំណេះដឹងដល់អ្នកអនុវត្តច្បាប់ក្នុងស្រុកក៏ដោយ ក៏ការផ្លាស់ប្តូរពិតប្រាកដនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាប្រហែលជាមិនអាចទៅរួចឡើយ ប្រសិនបើគ្មានការផ្លាស់ប្តូរជាមូលដ្ឋានណាមួយពីសំណាក់រាជរដ្ឋាភិបាល ចំពោះការប្តេជ្ញាចិត្តក្នុងការអនុវត្តឲ្យបាននីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា ។[៦]

ស្រដៀងគ្នានេះដែរ អ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហមមួយរូបទៀតបានបង្ហាញពីការយល់ឃើញរបស់ខ្លួនថា «ស្របពេលដែលសាលាក្តីខ្មែរក្រហមបានជួយពង្រឹងជំនាញរបស់ចៅក្រម និងមេធាវីក្នុងស្រុក ប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជានៅពុំទាន់មានការផ្លាស់ប្តូរនៅឡើយ ។»[៧]

**បទដ្ឋាននៃការអនុវត្តនីតិវិធីព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋអន្តរជាតិ**

ពាក់ព័ន្ធនឹងការអនុវត្តនីតិវិធី សាលាក្តីខ្មែរក្រហមបានប្រើប្រាស់វិធានផ្ទៃក្នុងដែលបង្កើតឡើងដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ដើម្បីដំណើរការនីតិវិធីសំណុំរឿងក្តី ។ ការអនុវត្តជាទូទៅ បានធ្វើឡើងដោយអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងមានលក្ខណៈល្អប្រសើរ ។ បទពិសោធន៍ដែលទទួលបានពីការអនុវត្តនីតិវិធីព្រហ្មទណ្ឌនៅសាលាក្តីខ្មែរក្រហមនៅក្នុងសំណុំរឿងដែលមានលក្ខណៈស្មុគស្មាញ ដូចជាសំណុំរឿង០០២ នឹងអាចក្លាយជាគំរូសម្រាប់មន្ត្រីអនុវត្តច្បាប់នៃស្ថាប័នតុលាការក្នុងស្រុក សិក្សា និងដកស្រង់បទពិសោធន៍នៅក្នុងការដំណើរការនីតិវិធីនៃសំណុំរឿងក្តីប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ។

វិធាននៃភស្តុតាងដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅត្រង់មាត្រា៣២១[៨] ហាក់បីដូចជាពុំបានចែងលម្អិតអំពីនីតិវិធីនៃការទទួលយកភស្តុតាង ហើយអត្ថន័យនៃ

---

៦ ដូចខាងលើ, ទំព័រ៧១ ។

៧ មជ្ឈមណ្ឌលឯកសារកម្ពុជា, Cambodia Law and Policy Journal, Michael G. Karnavas, *"Bringing Domestic Cambodian Cases into Compliance with International Standards"*, លេខទី១ ប្រចាំខែមករា ឆ្នាំ២០១៨ ។

៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា៣២១ (ការវាយតម្លៃលើភស្តុតាងដោយតុលាការ) បានចែងទាក់ទងនឹងវិធាននៃភស្តុតាងថា ៖

វិធាននេះទៀតសោត នៅមានលក្ខណៈចង្អៀត ពុំទាន់អាចយកទៅអនុវត្តបាននៅក្នុងរឿងក្ដីព្រហ្មទណ្ឌដែលមានលក្ខណៈស្មុគស្មាញ និងធំធេង ដូចជាករណីឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម ដែលមានភស្តុតាងយ៉ាងច្រើនលើសលុប ដែលដាក់ជូនដោយភាគី រង់ចាំអង្គជំនុំជម្រះធ្វើការវាយតម្លៃអំពីភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាន ។ ផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅត្រង់មាត្រា៨៧ស្ដីពីវិធាននៃភស្តុតាង បានចែងលម្អិតអំពីគោលការណ៍ នីតិវិធីនៃការទទួលយកភស្តុតាងដាក់ចូលក្នុងសំណុំរឿង និងបុព្វសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការវាយតម្លៃអំពីតម្លៃ និងទម្ងន់នៃភស្តុតាង ។[១៧] ដោយសារតែ ភស្តុតាងនៃឧក្រិដ្ឋកម្មដែលកើតឡើងក្នុងរបបខ្មែរក្រហម

---

«លើកលែងបទបញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី ។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើ ជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន ។

តុលាការសំអាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ។

ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង ។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ ។

ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន មិនអាចយកមកធ្វើជាភស្តុតាងបានឡើយ ។»

[១៧] វិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៨ ។

វិធាននៃភស្តុតាង :

១) លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក ។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ដើម្បីផ្ដន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

២) សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល ។

៣) អង្គជំនុំជម្រះសាលាដំបូង ធ្វើសេចក្ដីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី ។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ ។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖

ក) មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា

ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ) មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ) ច្បាប់មិនអនុញ្ញាត ឬ

ង) មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍ ។

មានចំនួនច្រើនលើសលុប ដូច្នេះការចែងលម្អិតអំពីវិធាននៃភស្តុតាងនឹងអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះងាយស្រួលក្នុងការកំណត់ថា តើភស្តុតាងណាដែលមានភាពជាប់ពាក់ព័ន្ធ និងមានភាពគួរឲ្យជឿជាក់បាន និងភស្តុតាងប្រភេទណាគួរត្រូវបានបដិសេធ ។

ការអនុវត្តវិធាននៃភស្តុតាងនៅក្នុងបរិបទនៃសំណុំរឿងក្តីស្មុគស្មាញ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងក្លាយជាបទពិសោធន៍ និងគំរូសម្រាប់ការអនុវត្តនីតិវិធីទាក់ទងនឹងវិធានភស្តុតាងនៅក្នុងតុលាការក្នុងស្រុក ។ ការធ្វើវិសោធនកម្មលើវិធាននៃភស្តុតាងដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា គួរតែត្រូវបានធ្វើឡើងដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកអនុវត្តច្បាប់ អាចយកវិធានទាំងនេះទៅអនុវត្តប្រកបដោយប្រសិទ្ធិភាពតាមគំរូបទដ្ឋានអន្តរជាតិ ។

## សេចក្តីសម្រេចសំខាន់ៗដែលអាចក្លាយជាយុត្តិសាស្ត្រសម្រាប់តុលាការក្នុងស្រុក

នៅក្នុងដំណាក់កាលមុនសវនាការ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពីបញ្ហាពាក់ព័ន្ធនឹងការសុំនៅក្រៅឃុំ និងលក្ខណៈវិនិច្ឆ័យសំខាន់ៗដើម្បីធ្វើយុត្តិកម្មចំពោះការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយយោងតាមសិទ្ធិក្នុងការទទួលបានសេរីភាពដូចមានចែងនៅក្នុងមាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាគោលការណ៍ណែនាំសម្រាប់តុលាការក្នុងស្រុក ។ ឧទាហរណ៍ នៅក្នុងសំណុំរឿង០០១ អង្គបុរេជំនុំជម្រះបានបញ្ជាក់លើបណ្តឹងឧទ្ធរណ៍ថា ការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើរូបជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច មានសារសំខាន់ពាក់ព័ន្ធនឹងមាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងវិធានផ្ទៃក្នុង ក្រោយ

---

៤) ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់ ។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣)ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ។

៥) អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការថ្លឹងថ្លែងពិចារណានូវចម្លើយសារភាព ដូចគ្នានឹងប្រភេទ នៃភស្តុតាងដទៃទៀតដែរ ។

៦) ក្នុងករណីដែលសហព្រះរាជអាជ្ញា និងជនជាប់ចោទព្រមព្រៀងគ្នាថា អង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានជំទាស់ទេ នោះអង្គជំនុំជម្រះអាចចាត់ទុកថា អង្គហេតុនោះត្រូវបានបញ្ជាក់ដោយភស្តុតាង ។

៧) ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវី គឺជាបុព្វសិទ្ធិពិសេស និងមិនអាចយកមកធ្វើជាភស្តុតាងបានឡើយ ។

៨) ប្រធានអង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យនាំយកវត្ថុតាងមកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះបាន ។

ពីធ្វើការពិចារណាយ៉ាងល្អិតល្អន់លើយុត្តិកម្មដែលបានប្រើប្រាស់ជាមូលដ្ឋាននៃការឃុំខ្លួន ។[១០] ទោះបីជាច្បាប់ក្នុងស្រុកមានចែងអំពីការសុំនៅក្រៅឃុំដោយមានការធានាក៏ដោយ ក៏ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជានៅតែបន្តពឹងផ្អែកលើការដាក់ពន្ធនាគារ ដែលជាជំហរដាច់ណាត់សម្រាប់ជនជាប់ចោទដែលរង់ចាំការជំនុំជម្រះក្តី ហើយសំណើសុំនៅក្រៅឃុំដោយមានការធានាកម្រនឹងទទួលបានការអនុញ្ញាតណាស់ ។[១១]

សវនាការស្តីពីការស្នើសុំនៅក្រៅឃុំនៅសាលាក្តីខ្មែរក្រហម គឺជាឧទាហរណ៍មួយយ៉ាងសំខាន់សម្រាប់តុលាការក្នុងស្រុក នៅពេលដែលព្រះរាជអាជ្ញាចាំបាច់ត្រូវតែស្វែងរកហេតុផលរឹងមាំដើម្បីស្នើសុំឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ហើយមេធាវីការពារក្តីឲ្យជនត្រូវចោទត្រូវតែមានសមត្ថភាពក្នុងការបង្ហាញអំពីអំណះអំណាង និងការជជែកតតាំងដើម្បីស្វែងរកមូលដ្ឋានប្រឆាំងនឹងការសម្រេចឃុំឃាំងកូនក្តីរបស់ខ្លួន ។ រីឯ ចៅក្រមត្រូវតែពិនិត្យពិច័យលើអំណះអំណាងទាំងនោះឲ្យបានគ្រប់ជ្រុងជ្រោយ និងចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុសមរម្យ ដោយផ្អែកលើការសន្មតអំពីសេរីភាពថាជាចំណុចចាប់ផ្តើម ។[១២]

សាលាក្តីខ្មែរក្រហមក៏បានបង្កើតយុត្តិសាស្ត្រដ៏មានសារប្រយោជន៍មួយចំនួន ស្តីពីលក្ខខណ្ឌដែលដាក់ឲ្យជនជាប់ចោទស្ថិតនៅក្រោមការឃុំខ្លួន ដោយរាប់បញ្ចូលទាំងការកំហិតរបស់តុលាការពាក់ព័ន្ធនឹង

---

[១០] មជ្ឈមណ្ឌលឯកសារកម្ពុជា, Cambodia Law and Policy Journal, Michael G. Karnavas, "*Bringing Domestic Cambodian Cases into Compliance with International Standards*", លេខទី១ ប្រចាំខែមករា ឆ្នាំ២០១៤ ។ សូមមើលផងដែរ "បណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងទៅនឹងសេចក្តីសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន", សូមមើលកំណត់សម្គាល់ជើងទំព័រទី១២, កថាខណ្ឌ៥៧ ។ អង្គបុរេជំនុំជម្រះបានរកឃើញថា ការឃុំខ្លួនបណ្តោះអាសន្នដោយការិយាល័យសហចៅក្រមស៊ើបអង្កេត គឺជាវិធានចំបាច់មួយដើម្បីបញ្ចៀសកុំឲ្យជនជាប់ចោទដាក់សម្ពាធលើ សាក្សី ឬជនរងគ្រោះ ដើម្បីបញ្ចៀសការបំផ្លាញភ័ស្តុតាង ដើម្បីធានាពីវត្តមានរបស់ជនជាប់ចោទក្នុងដំណើរការតុលាការ ដើម្បីការពារសុវត្ថិភាពរបស់ជនជាប់ចោទ និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ។ ការលើកឡើងពីហេតុផលសម្រាប់ការឃុំឃាំងបណ្តោះអាសន្នដោយយោងលើវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានរកឃើញថា ហេតុផលក្នុងការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នជារឿងត្រឹមត្រូវ ពីព្រោះបើសិនជាដោះលែង ជនជាប់ចោទអាចនឹងគំរាមកំហែងសាក្សី ។ វាជាការសំខាន់ដែលសាក្សីមិនមានការភ័យខ្លាច និងមិនទទួលរងសម្ពាធដោយសារការផ្តល់សក្ខីកម្ម ។ វាអាចជាហានិភ័យដែលជនជាប់ចោទអាចនឹងបាត់ខ្លួន បើសិនជាគាត់ត្រូវដោះលែងវានឹងអាចជាហានិភ័យចំពោះសុវត្ថិភាពរបស់ជនជាប់ចោទពីសំណាក់ជនរងគ្រោះ សាច់ញាតិបងប្អូន និងអតីតអ្នកធ្វើការនៅក្នុងគុកស-២១ និងផលប៉ះពាល់នៃរបបកម្ពុជាប្រជាធិបតេយ្យ ចំណាប់អារម្មណ៍របស់ប្រជាជនខ្មែរ និងក្រុមសារព័ត៌មានមកលើដំណើរការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការយល់ដឹងជាសាធារណៈនៃអត្តសញ្ញាណរបស់ជនជាប់ចោទ ដែលនាំឲ្យការដោះលែងជនជាប់ចោទអាចនឹងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ។

[១១] ដូចខាងលើ ។

[១២] ដូចខាងលើ ។

ការទាក់ទងរវាងជនជាប់ចោទជាមួយភរិយា[13] និងសិទ្ធិរបស់ជនជាប់ចោទដើម្បីចូលមើលឯកសារក្នុងសំណុំរឿងដោយអនុលោមតាមសិទ្ធិក្នុងការចូលរួមក្នុងការការពារខ្លួន និងដើម្បីធានាអំពីភាពស្មើគ្នាក្នុងការតតាំងក្ដីជាមួយនឹងព្រះរាជអាជ្ញា ។[14] សេចក្ដីសម្រេចដែលមានសារសំខាន់មួយទៀតនោះ គឺក្រមនីតិវិធីព្រហ្មទណ្ឌបានហាមប្រាមមេធាវីមិនឲ្យផ្ដល់សំណៅ ឬផ្នែកណាមួយនៃឯកសារក្នុងសំណុំរឿងទៅកូនក្ដីរបស់ខ្លួន[15] ដែលបានបង្កឲ្យមានការព្រួយបារម្ភជាខ្លាំងទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងចូលរួមក្នុងការការពារខ្លួន ជាពិសេសជនជាប់ចោទទាំងឡាយដែលពុំទាន់មានអ្នកតំណាង ។[16]

## គោលការណ៍ជាសារវន្តនៅក្នុងការសម្រេចសេចក្ដីពីសំណាក់ចៅក្រមវិជ្ជាជីវៈ

ការតម្រូវឲ្យចៅក្រមត្រូវតែចេញសេចក្ដីសម្រេចដែលមានសំអាងហេតុពេញលេញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថាជា “ការគោរពនូវសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌” ដែលជាយុត្តិសាស្ត្រមួយដ៏សំខាន់សម្រាប់តុលាការក្នុងស្រុក ពីព្រោះជារឿយៗការផ្ដល់សំអាងហេតុរបស់តុលាការនៅមានលក្ខណៈពុំទាន់ពេញលេញ ឬពេលខ្លះពុំមានតែម្ដង ។ សេចក្ដីសម្រេចជាច្រើនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញអំពីសមត្ថភាពរបស់តុលាការនេះក្នុងការធ្វើការប្រកបដោយ

---

[13] ដូចខាងលើ ។ សូមមើលបន្ថែម *សំណុំរឿង នួន ជា,* ០០២/១៩-០៩-២០០៧-អវតក, សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការទាក់ទងរវាងជនជាប់ចោទ និងភរិយារបស់ខ្លួន, កថាខណ្ឌ១៨ (ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨) (រកឃើញថា សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បញ្ចៀសទំនាក់ទំនងរវាងជនជាប់ចោទ អៀង សារី ជាមួយប្រពន្ធរបស់គាត់ ជនជាប់ចោទ អៀង ធីរិទ្ធ មិនត្រូវបានពន្យល់ហេតុផលឲ្យបានគ្រប់គ្រាន់នោះទេ ជាពិសេសមិនបានពន្យល់ថា តើការកំណត់ពីទំនាក់ទំនងនោះ គឺជាវិធានការសមាមាត្រចំបាច់ក្នុងការពារផលប្រយោជន៍នៃការស៊ើបអង្កេតដែរឬយ៉ាងណា) ។ អង្គបុរេជំនុំជម្រះក៏បានរកឃើញដែរថា ជនជាប់ចោទគួរត្រូវបានអនុញ្ញាតឲ្យជួបគ្នាដោយអនុលោមតាមវិធានដែលអនុវត្តនៅពេលស្ថិតនៅក្នុងមន្ទីរឃុំឃាំងបណ្ដោះអាសន្ន ។

[14] ដូចខាងលើ ។ សូមមើលបន្ថែម *សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ “ឌុច”* ០០១/១៨-០៧-២០០៧-អវតក-កសចអ, សហចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីបង្គាប់ឲ្យចូលមើលឯកសារសំណុំរឿងដោយជនជាប់ឃុំ (ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០០៩) ។ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានអនុវត្តយុត្តិសាស្ត្រពីតុលាការសិទ្ធិមនុស្សអឺរ៉ុបដែលទទួលស្គាល់ថា “មាននិន្នាការកំពុងកើនឡើងសម្រាប់តុលាការដែលទទួលស្គាល់ថា សិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមក្នុងការការពារក្ដីរបស់ខ្លួន និងសិទ្ធិទទួលការតតាំងដោយស្មើភាពគ្នា ជាមួយនឹងការចោទប្រកាន់ដែលតម្រូវឲ្យមានកម្រិតជាក់លាក់មួយនៃការទទួលបានសិទ្ធិក្នុងការចូលមើលឯកសារភ័ស្ដុតាងដោយ “ផ្ទាល់ និងពេញចិត្ត” ពីសំណាក់ជនជាប់ចោទ ។”

[15] ដូចខាងលើ ។ សូមមើលផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា១៨៩ បានចែងថា មេធាវីអាចអានផ្នែកណាមួយនៃឯកសារក្នុងសំណុំរឿងជូនកូនក្ដីខ្លួនបាន ប៉ុន្តែមិនត្រូវឲ្យសំណៅឯកសារដែលពាក់ព័ន្ធនឹងផ្នែកនោះទៅឲ្យកូនក្ដីខ្លួននោះទេ ។

[16] ដូចខាងលើ ។ សូមមើល កំណត់សម្គាល់ជើងទំព័រទី១០១ ។

ឯករាជ្យ មិនលម្អៀង និងការវិភាគយ៉ាងល្អិតល្អន់អំពីគោលការណ៍ច្បាប់អន្តរជាតិដែលមានលក្ខណៈស្មុគស្មាញ ជាជាងការទទួលយកភ្លាមៗនូវការបកស្រាយចំពោះអត្ថន័យនៃបទបញ្ញត្តិទាំងនោះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃផ្សេងទៀត ។ ឧទាហរណ៍ នៅក្នុងការពិចារណាអំពីភាពចម្រូងចម្រាសនៃការពង្រីកទម្រង់នៃសហឧក្រិដ្ឋកម្មរួម («សហឧក្រិដ្ឋកម្មរួមប្រភេទទី៣») ថាជាទម្រង់មួយនៃការទទួលខុសត្រូវ អង្គបុរេជំនុំជម្រះបានធ្វើការវិភាគស៊ីជម្រៅអំពីសមត្ថកិច្ចដែលធ្លាប់បានយកមកប្រើប្រាស់ពីពេលមុនដើម្បីគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋរួមប្រភេទទី៣ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាជាងការទទួលយកភ្លាមៗនូវអំណះអំណាងរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គូស្លាវីលើបញ្ហាដូចគ្នានេះ ។[១៧] ចំណុចនេះបានបង្ហាញពីភាពផ្ទុយគ្នានឹងសេចក្ដីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលរកឃើញថា ទំនួលខុសត្រូវប្រភេទនេះអាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយធ្វើការសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមប្រភេទទីបីមិនបានឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ នោះឡើយ ។[១៨] អង្គជំនុំជម្រះសាលាដំបូងបានគាំទ្រចំពោះសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។[១៩]

## ការអនុវត្តគោលការណ៍សិទ្ធិទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌

កិច្ចដំណើរការនីតិវិធីរបស់សាលាក្ដីខ្មែរក្រហម បានផ្ដោតជាសំខាន់ទៅលើគោលការណ៍ស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ ដែលក្នុងនោះមានដូចជា គោលការណ៍សន្មតថាគ្មានទោសដរាបណាពុំត្រូវបានផ្ដន្ទាទោស គោលការណ៍ទទួលបានសិទ្ធិស្មើភាពគ្នាក្នុងការតទល់ក្ដី ការតម្រូវឲ្យមានតម្លាភាពនៅក្នុងកិច្ចដំណើរការនីតិវិធី និងជាពិសេសការតម្រូវឲ្យមានការផ្ដល់សំអាងហេតុផលគ្រប់គ្រាន់ និងច្បាស់លាស់នៅក្នុងការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងការសម្រេចផ្ដន្ទាទោស ។ ការអនុវត្តគោលការណ៍ទាំងអស់នេះនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក ត្រូវបានមើលឃើញថាមានកម្រិត ហេតុដូច្នេះការអនុវត្តគោលការណ៍ទាំងនេះនៅសាលាក្ដីខ្មែរក្រហម នឹងអាចក្លាយជាគំរូល្អប្រសើរសម្រាប់ស្ថាប័នតុលាការជាតិ ជាពិសេសការអនុវត្តពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ ។

សិទ្ធិទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ គឺជា«ធាតុសំខាន់»ក្នុងការធ្វើឲ្យមាននីតិរដ្ឋដែលមានរួមបញ្ចូលនូវគោលការណ៍ស្ដីអំពីសិទ្ធិមនុស្ស ដែលចែងថា មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នា

---

[១៧] ដូចខាងលើ ។ សូមមើលកំណត់សម្គាល់ជើងទំព័រទី១០៣ ។

[១៨] ដូចខាងលើ ។ កថាខណ្ឌ៨៨ ។

[១៩] សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក/អជសជ, សេចក្ដីសម្រេចនៅការអនុវត្តសហឧក្រិដ្ឋកម្មរួម (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) ។

នៅចំពោះមុខច្បាប់ និងស្ថិតនៅក្រោមច្បាប់ និងគោរពតាមច្បាប់ ។[២០] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញឲ្យឃើញនូវសមត្ថភាពក្នុងការបកស្រាយ និងអនុវត្តបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ជាពិសេសពាក់ព័ន្ធនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ធ្វើជាកេរដំណែលរបស់ខ្លួន ។[២១]

ឧទាហរណ៍ទាក់ទងនឹងការពិចារណាលើសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ត្រៀមដើម្បីការពារខ្លួន និងសិទ្ធិក្នុងការទំនាក់ទំនងជាមួយមេធាវីដែលខ្លួនបានជ្រើសរើស ដោយយោងតាមមាត្រា១៨ នៃកតិកាសញ្ញាអន្តរជាតិស្តីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អង្គបុរេជំនុំជម្រះបានបង្គាប់ថា ដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបដិសេធមិនឲ្យក្រុមមេធាវីការពារក្តីធ្វើការថតសំឡេងពីជំនួបរវាង ជនជាប់ចោទ និងមេធាវីរបស់ខ្លួននៅមន្ទីរឃុំឃាំង បានរំលោភបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ។[២២] យោងតាមយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សនៃអឺរ៉ុប អង្គបុរេជំនុំជម្រះបានស្រាយយ៉ាងក្បោះក្បាយលើមាត្រា១៨ ដោយសម្រេចថា វិធីដែលការិយាល័យសហចៅក្រមស៊ើបអង្កេតអនុវត្តសិទ្ធិនេះក្នុងន័យចង្អៀត គឺ«ពុំស្របនឹងកម្មវត្ថុ និងគោលបំណងនៃការធានាការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ទេ ។»[២៣] ស្រដៀងគ្នានេះដែរ សាលាក្តីខ្មែរក្រហមបានចេញសេចក្តីសម្រេចដ៏សំខាន់មួយទៀត ស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុង

---

[២០] មជ្ឈមណ្ឌលឯកសារកម្ពុជា, Cambodia Law and Policy Journal, Michael G. Karnavas, "*Bringing Domestic Cambodian Cases into Compliance with International Standards*", លេខទី១ ប្រចាំខែមករា ឆ្នាំ២០១៤ ។

[២១] ដូចខាងលើ ។ សូមមើលផងដែរ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ហៅកាត់ថា (OHCHR), ដកស្រង់ពី *Rule of Law Tools in Post Conflict States: Maximizing the Legacy of Hybrid Courts*, United Nations, ៤-៥ (២០០៨), អាចរកបាននៅគេហទំព័រ www.ohchr.org/Documents/Publications/HybridCourts.pdf ។ ការិយាល័យឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិដើម្បីសិទ្ធិមនុស្ស បានរៀបរាប់ថា កេរដំណែលគឺជាទស្សនវិស័យយ៉ាងសំខាន់មួយរបស់តុលាការចម្រុះក្នុងការចូលរួមដើម្បីពង្រឹង«នីតិរដ្ឋនៅក្នុងសង្គមមួយតាមរយៈការអនុវត្តការជំនុំជម្រះក្តីដែលមានប្រសិទ្ធិភាពដើម្បីបញ្ចប់វប្បធម៌និទ្ទណ្ឌភាព ព្រមទាំងពង្រឹងសមត្ថភាពតុលាការ ។»

[២២] ដូចខាងលើ ។ សូមមើលកំណត់សម្គាល់ជើងទំព័រទី១០៦ «សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក/កសចអ(អបរជ ៦៤) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍, របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធចំពោះសំណើសុំដើម្បីថតសំឡេង/វីដេអូ នៃអំឡុងពេលនៃការជួបគ្នាជាមួយ អៀង សារី នៅក្នុងមណ្ឌលឃុំឃាំង (ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១០)» ។

[២៣] ដូចខាងលើ ។

សវនាការ[២៤] និងនីត្យានុកូលក្នុងការបន្តឃុំឃាំងដោយគ្មានការជំនុំជម្រះក្តី[២៥] ដែលអាចនឹងអនុវត្តដោយតុលាការក្នុងស្រុក ដើម្បីពង្រឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជាប់ចោទ ។

**សន្និដ្ឋាន**

តាមរយៈបទពិសោធន៍ផ្ទាល់ទាក់ទងនឹងកិច្ចការសង្កេតការណ៍អំពីកិច្ចដំណើរការនីតិវិធី និងការអនុវត្តការងារនៅសាលាក្តីខ្មែរក្រហម ខ្ញុំជឿជាក់ថា សាលាក្តីខ្មែរក្រហមនឹងក្លាយជាគំរូដ៏ល្អសម្រាប់ការធ្វើកំណែទម្រង់តុលាការ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតុលាការនៅក្នុងស្រុក ។ ជាពិសេស ការធ្វើកំណែទម្រង់លើការអនុវត្តពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីដែលផ្តោតលើការគោរពសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។

ថ្វីត្បិតមានការរំពឹងទុកខ្ពស់ទាក់ទងនឹងកេរដំណែល ប៉ុន្តែគេពុំត្រូវមើលរំលងឧបសគ្គចំបងៗដែលអាចនឹងគំរាមកំហែងដល់កិច្ចដំណើរការនីតិវិធី ដំណើរប្រព្រឹត្តទៅ និងកេរ្តិ៍ឈ្មោះនៃសាលាក្តីមួយនេះឡើយ ដូចជា បញ្ហាវ័យចាស់ជរា និងសុខភាពកាន់តែទ្រុឌទ្រោមរបស់ជនជាប់ចោទ និងជនរងគ្រោះ បញ្ហាថវិកា និងការចោទប្រកាន់អំពីការទទួលរងឥទ្ធិពលនយោបាយពីសំណាក់រាជរដ្ឋាភិបាលចំពោះការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែលជាភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាំបាច់ត្រូវធានាឲ្យបានអំពីឯករាជភាព សុចរិតភាព និងដំណើរប្រព្រឹត្តទៅរបស់តុលាការ ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងដើម្បីបន្សល់ទុកនូវកេរដំណែលគតិយុត្តិដ៏មានតម្លៃទាំងសម្រាប់ស្ថាប័នតុលាការជាតិរបស់កម្ពុជា និងស្ថាប័នតុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃផ្សេងទៀតក្នុងឋានៈជាតុលាការគំរូ ។

---

[២៤] ដូចខាងលើ ។ សុំមើលកំណត់សម្គាល់ជើងទំព័រទី១០៨ ៖ «សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក/អជសជ ការវាយតម្លៃសុខភាពជនជាប់ចោទសាជាថ្មីក្នុងការចូលរួមក្នុងសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១, កថាខណ្ឌ១៨-២១ (ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣) ។ ផ្អែកលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) និងគណៈវិនិច្ឆ័យពិសេស, អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់សាជាថ្មីពីការរកឃើញរបស់ខ្លួន ដែលជានជាប់ចោទ អៀង ធីរិទ្ធ ពុំមានកាយសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងការកាត់ក្តីបានទេ» ។

[២៥] ដូចខាងលើ ។ សុំមើលកំណត់សម្គាល់ជើងទំព័រទី១០៩ ៖ «កថាខណ្ឌ ១៩-២៣, អង្គជំនុំជម្រះវិសាមញ្ញបានធ្វើការពិចារណាលើយុត្តិសាស្ត្ររបស់តុលារព្រហ្មទណ្ឌអន្តរជាតិ តុលាការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការកំពូលរបស់សហរដ្ឋអាមេរិកនៅក្នុងការពិចារណាពីភាពស្របច្បាប់នៃការបន្តឃុំខ្លួន អៀង ធីរិទ្ធ ដោយសំអាងទៅលើការការពារអន្តរជាតិប្រឆាំងនឹងការឃុំខ្លួនដោយមិនមានពេលកំណត់ និងសិទ្ធិទទួលបានជំនុំជម្រះដោយគ្មានការពន្យារពេល ។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យមានការដោះលែង អៀង ធីរិទ្ធ ជាបន្ទាន់ ដោយផ្អែកលើមូលហេតុថា គ្មានមូលដ្ឋានសម្រាប់បន្តឃុំខ្លួនគាត់បន្តទៀត» ។